ASEAN AUSTRALIA SMART CITIES TRUST FUND
Asian Development Bank

Australian Government
Department of Foreign Affairs and Trade

ADB

RAMBOLL



# ការគ្រប់គ្រងហិរញ្ញវត្ថុ ទីក្រុងឆ្លាត

14 កញ្ញា និង 5 តុលា 2022

ស្កេនលេខកូដដើម្បីដាក់ពាក្យសម្រាប់កម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុទីក្រុងឆ្លាត ឬ ចូលមើល៖ BIT.LY/AASCTFAPPLY

មូលនិធិទីក្រុងឆ្លាតអាស៊ានអូស្ត្រាលី (AASCTF) យល់ថាការអភិវឌ្ឍសមត្ថភាពជាធាតុចូលដ៏សំខាន់មួយរបស់គម្រោង រួមជាមួយនឹងការគាំទ្របច្ចេកទេសសម្រាប់ប្រព័ន្ធរៀបចំផែនការ ការផ្តល់សេវា និងការគ្រប់គ្រងហិរញ្ញវត្ថុនៃទីក្រុងអាស៊ាន។ ចាប់តាំងពីមូលនិធិបានចាប់ផ្តើមក្នុងឆ្នាំ 2019 AASCTF បាននឹងកំពុងរៀបចំសិក្ខាសាលាណែនាំពីទីក្រុងឆ្លាតវៃនៅទូទាំងតំបន់ ដើម្បីមិនត្រឹមតែបង្ហាញពីរបៀបដែលមូលនិធិអាចផ្តល់អត្ថប្រយោជន៍ដល់ទីក្រុងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានការយល់ដឹងពីតម្រូវការរបស់ពួកគេ និងឱកាសសម្រាប់អន្តរាគមឆ្លាតវៃផងដែរ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងនេះ បច្ចុប្បន្ន យើង មានសេចក្តីសោមនស្សរីករាយក្នុងការបំពេញនូវអាទិភាពមួយក្នុងចំណោមអាទិភាពចម្បងដែលលើកឡើងដោយទីក្រុងនានាទាក់ទងនឹងចំណេះដឹង និងជំនាញដែលពួកគេចង់លើកកម្ពស់៖ គឺការគ្រប់គ្រងហិរញ្ញវត្ថុទីក្រុងឆ្លាត

## ហេតុអ្វីត្រូវការការគ្រប់គ្រងហិរញ្ញវត្ថុទីក្រុងឆ្លាត(SCFM)?

ទីក្រុង និងទីប្រជុំជនក្នុងតំបន់ ប្រឈមមុខនឹងបញ្ហាជាច្រើន ប៉ុន្តែដោយសារធនធានមានកម្រិត ជាពិសេសថវិការបស់រដ្ឋបាលមូលដ្ឋានអាចជាឧបសគ្គដល់កាដោះស្រាយបញ្ហាទាំងនោះ។ ទីក្រុងត្រូវបង្កើនសមត្ថភាពបង្កើតប្រាក់ចំណូល និងធ្វើពិពិធកម្មប្រភពចំណូលរបស់ខ្លួន ដើម្បីអាចមានលទ្ធភាពផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍក្រុង។

សិក្ខាសាលានេះ នឹងជួយឱ្យមន្ត្រីក្រុងអាចរៀបចំ ផែនទីបង្ហាញផ្លូវសម្រាប់តម្រូវការគោល និងធ្វើឱ្យការគ្រប់គ្រងហិរញ្ញវត្ថុរបស់គេប្រសើរឡើង រួមទាំងការបង្កើតកំណើនប្រាក់ចំណូលកាន់តែខ្លាំង។ អ្នកចូលរួមក៏នឹងកំណត់ វាយតម្លៃ និងប្រើប្រាស់ ឱកាស ហានិភ័យ និងការផ្លាស់ប្តូរដែលចាំបាច់សម្រាប់ការវិនិយោគប្រកបដោយប្រសិទ្ធភាព និងការប្រើប្រាស់ដំណោះស្រាយឆ្លាត។ ខ្លឹមសារនៃវគ្គសិក្សានឹងត្រូវបានរៀបចំដើម្បីធានានូវភាពអាចអនុវត្តបាននៃមេរៀន ដូច្នេះសិក្ខាកាមអាចរៀបចំយុទ្ធសាស្ត្រជាក់ស្តែង ឬករណីការងារមួយសម្រាប់ការវិនិយោគលើការគ្រប់គ្រងហិរញ្ញវត្ថុទីក្រុងឆ្លាតនៅក្នុងទីក្រុងរបស់ខ្លួន រួមទាំងការកំណត់នូវចន្លោះប្រហោងដែលត្រូវដោះស្រាយសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃគ្រប់គ្រងហិរញ្ញវត្ថុទីក្រុងឆ្លាតវៃ។

| 1 មិថុនា 2022 | 5 កក្កដា 2022 | ដើមខែសីហា 2022 | 14 កញ្ញា 2022 | 15 កញ្ញា ដល់ 4 តុលា 2022 | 5 តុលា 2022 |
|---|---|---|---|---|---|
| កម្មវិធីបើក | ថ្ងៃផុតកំណត់ទទួលពាក្យ | ពាក្យស្នើសុំទាំងអស់នឹងទទួលបានចម្លើយ | សិក្ខាសាលាវគ្គ 1 | លំហាត់អនុវត្តនៅផ្ទះ | សិក្ខាសាលាវគ្គ 2 |

## អ្នកចូលរួមដែលជាគោលដៅ

សិក្ខាសាលានេះរៀបចំឡើងសម្រាប់មន្ត្រីធ្វើការលើការគ្រប់គ្រងហិរញ្ញវត្ថុ អ្នកធ្វើការសម្រេចចិត្តផ្នែកហិ រញ្ញវត្ថុ និងបុគ្គលិករដ្ឋាភិបាលដែលពាក់ព័ន្ធនៅក្នុងមន្ទីរ ឬក្រសួងហិរញ្ញវត្ថុ។

## កាលវិភាគ និង រយៈពេល

វគ្គសិក្សានឹងមានពីរវគ្គ វគ្គនីមួយៗមានរយៈពេលកន្លះថ្ងៃ( 14 កញ្ញា និង 5 តុលា ) និងលំហាត់នៅផ្ទះ។ អ្នកចូលរួមនឹងចំណាយពេលយ៉ាងហោចណាស់ 15 ម៉ោង ចន្លោះវគ្គទាំងនេះ ដើម្បីធ្វើការលើករណីការងារ។

## ភាសា

វគ្គសិក្សានឹងធ្វើឡើងជាភាសាអង់គ្លេសដោយមានការបកប្រែប្រដេញពីចម្ងាយជាភាសា ឥណ្ឌូនេស៊ី ខ្មែរ ឡាវ និងវៀតណាម ដោយផ្អែកលើតម្រូវការ ។

## ការដាក់ពាក្យ

វគ្គនេះមិនគិតថ្លៃ ប៉ុន្តែកន្លែងកំណត់។ ថ្ងៃផុតកំណត់ទទួលពាក្យគឺថ្ងៃទី 5 កក្កដា។